**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ...៤៥៥.....ស.ភ.រ

# សេចក្តីជូនដំណឹង

អនុលោមតាមសេចក្តីសម្រេចលេខ២០៣៩ មស.សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០ សាលាភូមិន្ទរដ្ឋបាល សូមជូនដំណឹងដល់ សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់ជំនាញឡើងទៅ ព្រមទាំងសិស្ស និស្សិត ដែលនឹងបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដោយជោគជ័យ ក្នុងឆ្នាំ២០១៧នេះ ក៏ដូចជាមន្ត្រីរាជការទាំងអស់ ឲ្យបានជ្រាបថា សាលានឹងរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជាន់ខ្ពស់លើកទី១០ ចំនួន៦០នាក់ (ជំនាញរដ្ឋបាលទូទៅ ២០នាក់, សេដ្ឋកិច្ច-ហិរញ្ញវត្ថុ ២០នាក់, ជំនាញទំនាក់ទំនងអន្តរជាតិ ២០នាក់) ហើយបេក្ខជនត្រូវជ្រើសរើសជំនាញនិងភាសា ជាមុនក្នុងការដាក់ពាក្យ សម្រាប់ការបណ្តុះបណ្តាលឆ្នាំ២០១៨-២០១៩។

- លក្ខខណ្ឌនៃការជ្រើសរើស សូមមើលក្នុងសេចក្តីសម្រេចលេខ២០៣៩ មស.សសរ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- កាលបរិច្ឆេទបំពេញពាក្យតាម Online ចាប់ផ្តើមពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ តទៅ តាមគេហទំព័រ sms.era.gov.kh ឬអាចមកបំពេញពាក្យសុំប្រឡងតាម Online នៅសាលាភូមិន្ទរដ្ឋបាល
- កាលបរិច្ឆេទ នៃការទទួលពាក្យនឹងចាប់ផ្តើមពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ វេលាម៉ោង ១៧ម៉៣០នាទី ជាពេលផុតកំណត់
- សូមភ្ជាប់មកជាមួយនូវរូបថតថ្មី ៤x៦ ចំនួន៤សន្លឹក (ផ្ទៃខាងក្រោយពណ៌ស) និងឯកសារច្បាប់ដើម រួមមាន សំបុត្រកំណើត សញ្ញាបត្រ(ចាប់ពីបរិញ្ញាបត្រឡើងទៅ), អនុក្រឹត្យ ឬប្រកាស (សម្រាប់មន្ត្រីរាជការ) រួមទាំងច្បាប់ថតចម្លងដោយបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច
- ការប្រឡងប្រជែងនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ រីឯកាលបរិច្ឆេទជាក់ស្តែង នឹងត្រូវប្រកាសបិទផ្សាយជូននៅពេលក្រោយ និងនៅលើគេហទំព័ររបស់សាលាភូមិន្ទរដ្ឋបាល
- មុនពេលប្រឡង សាលានឹងមានបើកថ្នាក់រៀនត្រៀមសម្រាប់ការប្រឡងប្រជែងនេះផងដែរ ហើយការចុះឈ្មោះនឹងចាប់ផ្តើមពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧។ កាលបរិច្ឆេទនៃការចូលរៀនថ្នាក់ត្រៀមនឹងប្រព្រឹត្តទៅក្នុងអំឡុងខែសីហា ឆ្នាំ២០១៧ ។

<u>បញ្ជាក់៖</u>

- ការដាក់ពាក្យសុំសិទ្ធិប្រឡងតម្លៃ ៤៥.០០០៛(សែសិបប្រាំពាន់រៀលគត់)។

ចំពោះព័ត៌មានលំអិតផ្សេងៗទៀត មាននៅលើគេហទំព័រសាលា www.era.gov.kh ឬសូមទំនាក់ទំនងជាមួយការិយាល័យរដ្ឋបាល ឬតាមរយៈលេខទូរស័ព្ទ រៀងរាល់ម៉ោងធ្វើការដូចខាងក្រោម៖

- ព័ត៌មានក្នុងការបំពេញពាក្យ ទូរស័ព្ទលេខ ០១៧ ៨០៣ ៤២៦ -០៩៦ ៩៣៦៥ ២៧៧
- ព័ត៌មានទាក់ទងការប្រឡង ទូរស័ព្ទលេខ ០២៣ ៦២២ ២៦៦- ០៩៦ ៩៣២៧ ១៧៤

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧

**នាយកសាលា**

**យក់ ប៊ុនណា**

ចម្លងជូន៖
- សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ
- ឯកសារ -កាលប្បវត្តិ